លេខ: ០០៤ .១១ សកស សេអ៊ូល, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** សភាពការណ៍សេដ្ឋកិច្ចទូទៅ នៃសាធារណរដ្ឋកូរ៉េ និងទំនាក់ទំនង កម្ពុជា-កូរ៉េ ឆ្នាំ ២០១០

**តាមរយៈ: ឯកឧត្តមឯកអគ្គរាជទូត**

ខ្ញុំបាទមានកិត្តិយស សូមគោរពជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា សភាពការណ៍សេដ្ឋកិច្ច នៃប្រទេសកូរ៉េ នាបច្ចុប្បន្នកាលនេះ បាននិងកំពុង តែមានសញ្ញាវិជ្ជមាន ដោយសេដ្ឋកិច្ចមានកម្លាំងងើបស្ទុះឡើងវិញ ជាកត្តាធ្វើអោយកូរ៉េ សំរេចបានទូវសម្មិទ្ធិផលធំៗ ជាច្រើនទាឆ្នាំ ២០១០ កន្លងមក ។

កាលពីឆ្នាំ ២០១០ ការនាំចេញទំនិញ របស់ប្រទេសកូរ៉េ បានឈានទៅដល់ លំដាប់លេខ ៧ ក្នុងចំណោមបណ្តាប្រទេសសំខាន់ៗ នាំចេញបរិមាណច្រើនបំផុត នៅលើពិភពលោក ។ ទូរលេខនាំចេញ នាឆ្នាំ ២០១០ នោះគឺ 467.4 Billion USD ក្នុងខណ:ទូរលេខនាំចូល មានចំនួនប្រមាណ 425.7 Billion USD ធ្វើអោយជញ្ជីងពាណិជ្ជកម្មវិជ្ជមាន របស់ប្រទេសកូរ៉េ មានទឹកប្រាក់នៅសល់ (Trade Surplus) រហូតដល់ 41.7 Billion USD ។

តែនៅឆ្នាំ ២០១១ នេះ បើសិនជាតម្លៃប្រេងឥន្ទន: នៅតែមានតម្លៃខ្ពស់រហូតពេញ ១ឆ្នាំនោះ Trade Surplus នឹងអាចធ្លាក់ចុះមកត្រឹមបរិមាណ ប្រហែលជា 25 Billion USD ដោយសារតែការកើនឡើង នូវតម្រូវការវត្ថុធាតុដើម និងប្រេងឥន្ទន: និងបរិក្ខាផ្សេងទៀតសំរាប់បំរើការផលិត ដើម្បីនាំចេញ ។

ពាណិជ្ជកម្មទ្វេទិស របស់កូរ៉េ ក្នុងឆ្នាំ ២០១១ នេះ រំពឹងគិតថា នឹងឈានទៅដល់បរិមាណ 1.000 Billion USD ។

តាមការប៉ាន់ស្មាន របស់បណ្តាស្ថាប័នសំខាន់ៗ កូរ៉េ បានអោយដឹងថា កំណើនសេដ្ឋកិច្ច ស.កូរ៉េ នាឆ្នាំ ២០១០ កន្លងមក មានកំរិតប្រមាណជា 6.1% ហើយនៅឆ្នាំ ២០១១ នេះ សេដ្ឋកិច្ចមានសន្ទុះកើនឡើងប្រមាណជា 5% ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប អំពី**សភាពការណ៍សេដ្ឋកិច្ចទូទៅ ឆ្នាំ ២០១០ និងទំនាក់ទំនង កម្ពុជា-កូរ៉េ** ដូចតទៅ :

## I. កម្ពុជា នាំចេញទៅកូរ៉េ ប្រចាំខែ នាឆ្នាំ ២០០៩ ប្រៀបធៀបឆ្នាំ ២០១០

តម្លៃគិតជា ១000 ដុល្លារ






កម្ពុជា នាំចេញទៅ កូរ៉េ ឆ្នាំ ២០០៩

កម្ពុជា នាំចេញទៅ កូរ៉េ ឆ្នាំ ២០១០

យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើៈ រយៈពេល ១១ ខែ ពីមករា ដល់ វិច្ឆិកា នាឆ្នាំ ២០១០ កន្លងមកនេះ **ទំនិញនាំចេញ ពីកម្ពុជា មកប្រទេសកូរ៉េ** មានទឹកប្រាក់ 40,285,000 US$ កំណើនមធ្យមភាគ កើនឡើងចំនួន 237% ប្រៀបធៀប រយៈពេល១១ខែដូចគ្នា នាឆ្នាំ ២០០៩ ដែលមានទឹកប្រាក់ ចំនួន 15,583,000 US$ ។

បរិមាណនាំចេញ **ពីកម្ពុជា ទៅកូរ៉េ** ឆ្នាំ ២០០០ ដល់ឆ្នាំ ២០១០ **គិតជាពាន់ ដុល្លារ អាមេរិក**



## II. *កូរ៉េ នាំចេញទៅ កម្ពុជា ប្រចាំខែ នាឆ្នាំ ២០០៩ ប្រៀបធៀបឆ្នាំ ២០១០ តម្លៃគិតជា ១០០០ ដុល្លារ*




*កូរ៉េ នាំចេញទៅ កម្ពុជា ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ ២០០៩*

*កូរ៉េ នាំចេញទៅ កម្ពុជា ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ ២០១០*

*យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើៈ រយៈពេល ១១ ខែ ពីខែមករា ដល់ខែវិច្ឆិកា នាឆ្នាំ ២០១០ នេះ **ទំនិញនាំចេញ ពីប្រទេសកូរ៉េ មកកម្ពុជា** មានទឹកប្រាក់ 299,206,000 US$ កំណើនមធ្យមភាគ កើនឡើងចំនួន 26% ប្រៀបធៀប រយៈពេល១១ខែដូចគ្នា នាឆ្នាំ ២០០៩ ដែលមានទឹកប្រាក់ ចំនួន 240,602,000 US$ ។*

*បរិមាណនាំចេញ **ពីកូរ៉េ ទៅកម្ពុជា** ឆ្នាំ ២០០០ ដល់ឆ្នាំ ២០១០ **គិតជាពាន់ ដុល្លារ អាមេរិក***



## *III. ទូរលេខ ពាណិជ្ជកម្ម **កូរ៉េ-ពិភពលោក ឆ្នាំ ២០០៩ និង ឆ្នាំ ២០១០***

| | | **នាំចេញ** | **នាំចូល** | **Trade Balance** |
|---|---|---|---|---|
| 2009 | ឆមាសទី ១ | $ 164.8 billion | $ 145.4 billion | $ 19.4 billion |
| | ឆមាសទី ២ | $ 198.8 billion | $ 177.7 billion | $ 21.1 billion |
| | **Whole year 2009** | **$ 363.5 billion** | **$ 323.1 billion** | **$ 40.4 billion** |
| 2010 | ឆមាសទី ១ | $ 221.4 billion (34.3%) | $ 203.9 billion (40.2%) | $ 17.5 billion |
| | ឆមាសទី ២ | $ 246.0 billion (23.7%) | $ 221.8 billion (24.8%) | $ 24.2 billion |
| | **Whole year 2010** | **$ 467.4 billion (28.6%)** | **$ 425.7 billion (31.8%)** | **$ 41.7 billion** |

*ផលិតផល ស,កូរ៉េ សំខាន់ៗ ដែលបាននាំចេញ ឆ្នាំ ២០១០*

| **ផលិតផល សំខាន់ៗ នាំចេញ ២០១០** | **តម្លៃទំនិញនាំចេញ** | **កំណើន** |
|---|---|---|
| Semiconductors | $50.68 billion | 63.3% |
| Textiles | $13.92 billion | 19.6% |
| Petroleum Products | $31.49 billion | 37.1% |
| General Machinery | $36.22 billion | 34.9% |
| Petrochemicals | $35.7 billion | 30% |
| LCD Devices | $29.95billion | 27.8% |
| Steel | $28.89 billion | 25.4% |
| Automobiles | $35.4 billion | 39.3% |
| Household Appliances | $12.84 billion | 27.7% |
| Automobile Prats | $19.04 billion | 62.6% |
| Computers | $9.08 billion | 13.3% |
| Ships | $49.75 billion | 10.2% |
| Wireless Communication Devices | $27.41 billion | -11.6% |

*ពាណិជ្ជកម្ម* ***កូរ៉េ-ពិភពលោក ២០០៤ ដល់ ២០១០*** *តម្លៃគិតជា ១០០០ ដុល្លារ*




កូរ៉េនាំចេញទៅប្រទេសសំខាន់ ១០ ទូរលេខគិតជា លានដុលារ ១១ខែ ឆ្នាំ ២០១០






## ***VI. វិស័យទេសចរណ៍ កម្ពុជា-កូរ៉េ***

*ទេសចរណ៍ **កូរ៉េ** មក **កម្ពុជា** បានកើន ពី ៦២.២៧១ នាក់ (ចំណាត់ថ្នាក់លេខ ៣) ក្នុង ឆ្នាំ ២០០៣ រហូតដល់ **២១៦.៥៨៤ នាក់** (ចំណាត់ថ្នាក់លេខ ១) ក្នុងឆ្នាំ ២០០៤ ក្នុងឆ្នាំ ២០០៥ មាន **២១៦.៥៨៤ នាក់** នៅឆ្នាំ ២០០៦ មាន **២៨៥.៣៥៣នាក់** , នៅឆ្នាំ ២០០៧ មាន **៣២៩.៩០៩នាក់**, និងនៅឆ្នាំ ២០០៨ មានចំនួន **២៦៦.៣៧០នាក់** ។*




*ទូរលេខក្រសួងទេសចរណ៍កម្ពុជា*

*ចំនួនទេសចរណ៍កូរ៉េមកកម្ពុជា ទទួលចំណាត់ថ្នាក់ លេខ ១ តាំងពីឆ្នាំ ២០០៤ រហូតមកទល់ ឆ្នាំ ២០០៨ ។*

*ក៏ប៉ុន្តែចាប់ពីឆ្នាំ ២០០៩ នេះ ចំនួនទេសចរណ៍ **វៀតណាម** មកកម្ពុជា បានទទួលចំណាត់ថ្នាក់ លេខ ១ វិញម្តង ។ **ទេសចរណ៍កូរ៉េ ទៅកម្ពុជា រយៈពេល ៥ខែដើមឆ្នាំ ២០១០ នេះ មានចំនួន 125,455 នាក់ កើនឡើង 33.53% ប្រៀបធៀប រយៈពេលដូចគ្នា ឆ្នាំ ២០០៩។ ទេសចរណ៍កូរ៉េ ទៅកម្ពុជា នាឆ្នាំ ២០១០ នេះ មានចំនួនប្រមាណជា 272,000 នាក់ ។***

កូរ៉េ គឺជាទីផ្សារដ៏សំខាន់មួយ សំរាប់វិស័យទេសចរណ៍របស់កម្ពុជា នៅឆ្នាំ ២០១០ កន្លងមក ចំនួនអ្នកទេសចរណ៏ កូរ៉េ ចូលទៅកម្ពុជា កើនឡើងជិត ៤០ភាគរយ ។ អ្នកទេសចរណ៏កូរ៉េ ភាគច្រើនមកទស្សនា និងស្នាក់នៅកម្ពុជា រយៈពេលជាមធ្យម ៣ថ្ងៃ ប្រហាក់ប្រហែលនឹងការស្នាក់នៅរបស់អ្នកទេសចរណ៏ជប៉ុនដែរ តែការស្នាក់នៅ របស់អ្នកទេសចរណ៏អឺរ៉ុប មានរយៈពេលជាមធ្យម ៥ថ្ងៃ ។

**វិស័យទេសចរណ៏ កូរ៉េ:** នាឆ្នាំ ២០១០ កន្លងមក ទេសចរណ៏បរទេស បានហូរចូលប្រទេសកូរ៉េ មានចំនួនប្រមាណ 8.8 Million កើនឡើង 12.5% ប្រៀបធៀបឆ្នាំ ២០០៩ ដែលមានចំនួន 7.82 Million នាក់ ។ រដ្ឋាភិបាលមានទិសដៅ និងគោលនយោបាយ ទាក់ទាញ ទេសចរណ៏បរទេស អោយបានចំនួន 10 Million នាក់ នាឆ្នាំ ២០១២ ដែលចំនួនអ្នកទេសចរណ៏បរទេសនេះ នឹងអាចធ្វើអោយប្រទេសមានលទ្ធភាពស្រូបទាញរូបិយប័ណ្ណបរទេសប្រមាណ 10 Billion USD ការបង្កើតការងារថ្មី ៧ ថែមទៀត ព្រមទាំងការបង្កើនមុខមាត់ របស់ខ្លួនលើឆាកអន្តរជាតិ ។

**កំណត់សំគាល់:** បន្ទាប់ពីឆ្នាំ ២០១០ ដែលសេដ្ឋកិច្ចកូរ៉េ បានទទួលកំណើនប្រមាណ 6.1% នៅឆ្នាំ ២០១១ រដ្ឋាភិបាល ស.កូរ៉េ មានគោលដៅសំខាន់ៗ តាមរយៈកិច្ចពង្រឹងការលើកកំពស់ ជ្រោងកំណើនសេដ្ឋកិច្ចលើសពី 5% ការទ្រទ្រង់រក្សាអត្រាអតិផរណាអោយស្ថិតនៅក្រោម 3% ការបង្កើតការងារសមរម្យថ្មីៗ ថែមទៀត ( កាលពីឆ្នាំ ២០១០ បង្កើនការងារថ្មី បានចំនួនប្រមាណ ៣១០,០០០ នាក់ ) លើកកំពស់អោយកាន់តែប្រសើរឡើង នូវគុណភាពជីវភាពរស់នៅ របស់ប្រជាជន ដែលមានចំណូល ទាប និង មធ្យម ។ល។

បន្ទាប់ពីការប្រឹងប្រែងពុះពាររើបំរះ ក្នុងរយៈពេលដ៏ខ្លី សេដ្ឋកិច្ចរបស់ ស.កូរ៉េ បានរះភ្លឺឡើងលើឆាកអន្តរជាតិ ដោយបានប្រែក្លាយ ឈានដល់ជាប្រទេសឧស្សាហកម្មជឿនលឿន ហើយបានបង្កើនតួនាទីសេដ្ឋកិច្ច-ហិរញ្ញវត្ថុសំខាន់ៗ ជាមួយបណ្តាប្រទេស G20 ព្រមទាំងបានទទួលនាទី ធ្វើជារដ្ឋម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំ G20 និងសន្និសីទអន្តរជាតិជាច្រើនទៀត ។

ទន្ទឹមនឹងការប្រែក្លាយខ្លួនទៅជា ប្រទេសដែលមានសេដ្ឋកិច្ចឈានមុខនោះ ស.កូរ៉េ បានធ្វើការអភិវឌ្ឍន៏យ៉ាងខ្លាំងក្លា ដែលមួយចំនួនធំ ចេញពីប្រភពដើមនៃបច្ចេកវិទ្យារបស់ខ្លួន ដោយរដ្ឋាភិបាល បាននិងកំពុង គាំទ្រពង្រឹងវិស័យវិទ្យាសាស្ត្រ វិស័យបច្ចេកវិទ្យា វិស័យវិស្វកម្ម ការអភិវឌ្ឍន៏ធនធានមនុស្ស ការបង្កើនសក្តានុពលក្នុងការប្រកួតប្រជែងផលិតផល ទាំងក្នុង និង ក្រៅប្រទេស ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំបាទ ។

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងសេអ៊ូល**

**យឺវ សុខុម**

**បានឃើញ និង ឯកភាព**
**ដើម្បីជូនជ្រាបជារបាយការណ៍ ដ៏ខ្ពង់ខ្ពស់**
**ឯកអគ្គរាជទូត**

**ចាន់ គីស៊ីម**

កាលពីឆ្នាំ ២០១០ ការនាំចេញទំនិញ របស់ប្រទេសកូរ៉េ បានឈានទៅដល់ លំដាប់លេខ ៧ ក្នុងចំណោមបណ្ដាប្រទេសសំខាន់ៗ នាំចេញបរិមាណច្រើនបំផុត នៅលើពិភពលោក ។ ទូរលេខនាំចេញ នាឆ្នាំ ២០១០ នោះគឺ 467.4 Billion USD ក្នុងខណ:ទូរលេខនាំចូល មានចំនួនប្រមាណ 425.7 Billion USD ធ្វើអោយជញ្ជីងពាណិជ្ជកម្មវិជ្ជមាន របស់ប្រទេសកូរ៉េ មានទឹកប្រាក់នៅសល់ (Trade Surplus) រហូតដល់ 41.7 Billion USD ។

តែនៅឆ្នាំ ២០១១ នេះ បើសិនជាតម្លៃប្រេងឥន្ទន: នៅតែមានតម្លៃខ្ពស់រហូតពេញ ១ឆ្នាំនោះ Trade Surplus នឹងអាចធ្លាក់ចុះមកត្រឹមបរិមាណ ប្រហែលជា 25 Billion USD ដោយសារតែការកើនឡើង នូវតម្រូវការវត្ថុធាតុដើម និងប្រេងឥន្ទន: និងបរិក្ខាផ្សេងទៀតសំរាប់បំរើការផលិត ដើម្បីនាំចេញ ។

កម្ពុជា នាំចេញទៅ កូរ៉េ ឆ្នាំ ២០០៩

កម្ពុជា នាំចេញទៅ កូរ៉េ ឆ្នាំ ២០១០

យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើ: រយ:ពេល ១១ ខែ ពីមករា ដល់ វិច្ឆិកា នាឆ្នាំ ២០១០ កន្លងមកនេះ **ទំនិញនាំចេញ ពីកម្ពុជា មកប្រទេសកូរ៉េ** មានទឹកប្រាក់ 40,285,000 US$ កំណើនមធ្យមភាគ កើនឡើងចំនួន 237% ប្រៀបធៀប រយ:ពេល១១ខែដូចគ្នា នាឆ្នាំ ២០០៩ ដែលមានទឹកប្រាក់ ចំនួន 15,583,000 US$ ។

កូរ៉េ នាំចេញទៅ កម្ពុជា ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ ២០០៩

កូរ៉េ នាំចេញទៅ កម្ពុជា ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ ២០១០

យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើ: រយ:ពេល ១១ ខែ ពីខែមករា ដល់ខែវិច្ឆិកា នាឆ្នាំ ២០១០ នេះ **ទំនិញនាំចេញ ពីប្រទេសកូរ៉េ មកកម្ពុជា** មានទឹកប្រាក់ 299,206,000 US$ កំណើនមធ្យមភាគ កើនឡើងចំនួន 26% ប្រៀបធៀប រយ:ពេល១១ខែដូចគ្នា នាឆ្នាំ ២០០៩ ដែលមានទឹកប្រាក់ ចំនួន 240,602,000 US$ ។

កិច្ចដំណើរការកសាងសេដ្ឋកិច្ចរបស់ សា.កូរ៉េ ដើបឡើងយ៉ាងរហ័ស ទទួលបានកំណើន 6.1% នាឆ្នាំ ២០១០ ហើយនៅឆ្នាំ នេះ ២០១១ នឹងទទួលបាន 5% ទោះបីជាសេដ្ឋកិច្ច នៅបណ្តាប្រទេសអឺរ៉ុប មានកំណើនយឺត ហើយមានប្រទេសខ្លះ នៅតែ មានឱនភាព នៅឡើយក៏ដោយ ។ ដោយសង្កេតជារួមឃើញថា ប្រទេសនៅតំបន់ អាស៊ី-ប៉ាស៊ីហ្វិក រួមទាំងកម្ពុជាផងដែរ គឺមានស្ថេរភាពសេដ្ឋកិច្ច ផ្តល់នូវបរិស្ថានវិនិយោគ-ពាណិជ្ជកម្ម មានលក្ខណ:ល្អប្រសើរ ។

សកម្មភាពនៃការវិនិយោគ និងការធ្វើពាណិជ្ជកម្ម កូរ៉េ នៅកម្ពុជា នាពេលបច្ចុប្បន្ន មានលក្ខណ:លេចធ្លោ ព្រមទាំងឈានមុខ លើវិស័យ ៨ សំខាន់ៗ គឺ: វិនិយោគ ទេសចរណ៍ ការបណ្ដុះបណ្ដាលមុខវិជ្ជាជីវ: ព័ត៌មានវិទ្យា ហិរញ្ញវត្ថុ



*សំណង់ សេវាកម្មទេសចរណ៍ និងវប្បធម៌ ហើយទំនាក់ទំនងពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ មានការកើនឡើងទៅមុខជាលំដាប់ ទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ ។*

*ចំណាប់អារម្មណ៍លើបទអន្តរាគមន៍: សេដ្ឋកិច្ចរីកចំរើនឡើង ទាំងប្រទេសអ្នកមាន និងប្រទេសកំពុងអភិវឌ្ឍន៍ ធ្វើអោយមានការកើនឡើងនូវតម្រូវការ ទាំងក្នុងនិងក្រៅប្រទេស កំណើនលើការផលិតនិងផ្គត់ផ្គង់ ព្រមជាមួយនោះតម្រូវការថាមពលក៏កើន អតិផរណាក៏កើន តម្លៃម្ហូបអាហារក៏កើន តម្លៃរបស់របរប្រើប្រាស់ក៏កើន ។ ដូច្នេះហើយធ្វើអោយបណ្តាប្រទេសសំខាន់ៗ មួយចំនួន មានវិធានការណ៍ទប់ទល់អតិផរណា រឹតបន្តឹងការត្រួតពិនិត្យតម្លៃទំនិញ ការតម្លើងការប្រាក់នៅធនាគារ បង្កើនការងារសមរម្យ,,,, ។ អំពីការងាយស្រួល ពាណិជ្ជកម្ម សេដ្ឋកិច្ច វិនិយោគ ទេសចរណ៍,,,ស្ថេរភាពសេដ្ឋកិច្ច ,,,*

*រូបិយប័ណ្ណចិន នឹងបង្កើនតួនាទី-ការប្រើប្រាស់ នៅទីផ្សារអន្តរជាតិ តាមរយៈជំហានដំបូង គឺការធ្វើពាណិជ្ជកម្មទូទាត់-វិនិយោគ ធនាគារនេះទៅតាម ព្រមពេលនោះនឹងអនុញ្ញាតការទូទាត់ជាប្រាក់ យ៉ន់ ។*

*ចំពោះសកម្មភាពការងារ គឺចុំរុះ,,,,,,,,,,,,,,*

*ចុងក្រោយ និយាយជំរាបអំពី ទំនាក់ទំនងល្អ ពិសេសជាមួយថ្នាក់ដឹកនាំ និងការជួបថ្នាក់ដឹកនាំកំពូលរបស់កូរ៉េ*

*ការជូនពរ ឆ្នាំថ្មី*


Dec
Nov
Oct
Sept
Aug
July
June
May
Apr
Mar
Feb
2,619
4,766
1,106
3,535
2,136
4,007
2,136
3,158
1,933
2,184
2,133
5,717
1,803
3,596
710
2,849
702
4,286
1,643
1,857